archive.today
webpage capture
Saved from https://m.freshnewsasia.com/index.php/en/business/311575-2023-09-25-08- search
no other snapshots from this url
4 Jan 2024 07:09:08 UTC
All snapshots from host m.freshnewsasia.com
Webpage Screenshot
share download .zip report bug or abuse Buy me a coffee










# កម្ពុជាចម្រាញ់រ៉ែមាសបានជាង ៨ ២៨៨គីឡូក្រាម ទទួលចំណូលពីសួយសារជាង ១៣លានដុល្លារ (Video inside)

2023-09-25 03:35pm




**(ភ្នំពេញ)៖** គិតត្រឹមថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣នេះ កម្ពុជាចម្រាញ់រ៉ែមាសបានជាង ៨ ២៨៨គីឡូក្រាម និងទទួលបានចំណូលពីសួយសារ ជាង ១៣លានដុល្លារអាមេរិក។ នេះបើតាមការបញ្ជាក់ឲ្យដឹងពី លោក អ៊ឹង ឌីប៉ូឡា អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងរ៉ែ និងថាមពល។

ថ្លែងប្រាប់បណ្តាញព័ត៌មាន Fresh News នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣នេះ លោក អ៊ឹង ឌីប៉ូឡា បានបញ្ជាក់ថា **«គិតត្រឹមថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមហ៊ុនទាំង៦ បានផលិតដុំមាស ចំនួន៩១៩ដុំ ស្មើនឹងជាង ៨ ២៨៨គីឡូក្រាម និងបានបង់សួយសារ ជាង១៣លានដុល្លារ»**។

**លោក អ៊ឹង ឌីប៉ូឡា បានគូសបញ្ជាក់ថា ក្រុមហ៊ុនចំនួន៦ ដែលកំពុងតែចម្រាញ់រ៉ែមាស នៅក្នុងប្រទេសកម្ពុជា រួមមាន៖**

ទី១៖ ក្រុមហ៊ុន Renaissance Minerals (Cambodia) Ltd ស្ថិតក្នុងតំបន់អូរខ្វាវ ស្រុកកែវសីម៉ា ខេត្តមណ្ឌលគិរី
ទី២៖ ក្រុមហ៊ុន Xinshan ស្ថិតនៅក្នុងតំបន់ភ្នំម្លូង ខេត្តព្រះវិហារ
ទិ៣៖ ក្រុមហ៊ុន ឌែលខម (Delcom Cambodia) ស្ថិតនៅក្នុងតំបន់ភ្នំម្លូង ខេត្តព្រះវិហារ
ទី៤៖ ក្រុមហ៊ុន Rong Cheng ស្ថិតនៅតំបន់ចុងផ្លាស់ ខេត្តមណ្ឌលគិរី
ទី៥៖ ក្រុមហ៊ុន Xing Yuan ស្ថិតនៅតំបន់អូរត្រួន ខេត្តក្រចេះ
ទី៦៖ ក្រុមហ៊ុន LATE CHENG MINING DEVELOPMENT CO., LTD ស្ថិតតំបន់ភ្នំជី ខេត្តកំពង់ធំ។

បន្ថែមពីនោះទៀត លោក អ៊ឹង ឌីប៉ូឡា បានឲ្យដឹងថា ក្រុមហ៊ុនទាំង៦នេះ កំពុងតែចម្រាញ់រ៉ែមាស ទៅតាមផែនការ ដែលឯកភាព ជាមួយនឹងក្រសួងរ៉ែ និងថាមពល ហើយ អនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិជាធរមាននានា ដោយមិនមានជាបញ្ហាអ្វីនោះទេ។

ក្នុងចំណោមក្រុមហ៊ុនទាំង៦នេះ គឺក្រុមហ៊ុន Renaissance Minerals នៅខេត្តមណ្ឌលគិរី ទទួលបានទិន្នផលខ្ពស់ជាងគេ ប្រមាណជាង ៧ ៨៤៦គីឡូក្រាម ខណៈ៥ក្រុមហ៊ុនទៀត ទទួលបានផលតិចតួចប៉ុណ្ណោះ៕













3.50$
Ming Palace


011/016-20 20 20
Online Booking : www.larryta.com


$999
061 888 279
071 7 888 279
081 929 888
071 929 888 9
31-12-23


EMPIRE MANSION
19.2m x 13.5m
085 75 6666


UNIVERSITY OF INDRAWICHEA

90%

Copyright © 2021 FN Media Co.,Ltd.

Data Center By Fresh News




100%

